**ធម្មទេសនារបស់លោកអភិបាលអូលីវីយេ**
**អភិបូជាបិទកម្មវិធីបោះជំរំសម្រាប់ការត្រាស់ហៅនៅកំពង់សោម**
**ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៨**
*ខ្ញុំជួយ១០០នាក់មិនបាន ប៉ុន្តែយ៉ាងតិចខ្ញុំជួយម្នាក់*

អត្ថបទទី១៖ អស ៣៥,៤-៧ក
អត្ថបទទី២៖ យក ២,១-៥
ដំណឹងល្អ៖ មក ៨,៣១-៣៧

បងប្អូនជាទីស្រឡាញ់!

តើបងប្អូនមករកអ្វីនៅទីនេះ? ក្នុងរយៈពេលប៉ុន្មានថ្ងៃនេះ យើងមានទាំងការអធិដ្ឋាន ការអប់រំ អំណរសប្បាយរួមគ្នា ខ្ញុំសង្ឃឹមថាចូលនៅក្នុងដួងចិត្តរបស់បងប្អូន ដើម្បីឆ្លើយនឹងសំណួរដែលព្រះយេស៊ូសួរថា តើបងប្អូនមករកអ្វី? ព្រះបន្ទូលទីពីរដែលយើងបានស្តាប់ "**សូមអញ្ជើញមក អ្នកនឹងឃើញ**" ព្រះបន្ទូលទីបីដែលយើងបានស្តាប់ "**កុំខ្លាចអី!**" ព្រះបន្ទូលទីបួនដែលយើងបានស្តាប់ "**ខ្ញុំជាអ្នកបម្រើរបស់ព្រះជាម្ចាស់ សូមបានសម្រេចតាមព្រះហឫទ័យរបស់ព្រះអង្គចុះ**"។ ថ្ងៃនេះ យើងបានស្តាប់ព្រះបន្ទូលមួយទៀតថា "**អេហ្វាថា ប្រែថា ចូរបើកឡើង!**" សម្រាប់អ្នកថ្លង់បើកត្រចៀក សម្រាប់អ្នកខ្វាក់បើកភ្នែក សម្រាប់អ្នកដែលងងឹតបើកដួងចិត្តឲ្យមើលឃើញ។ យើងបានធ្វើដំណើរជាមួយព្រះយេស៊ូ យើងមករកអ្វី? ចូរមកតាមខ្ញុំអ្នកនឹងឃើញ! យើងភ័យ កុំខ្លាចអី! ណែនាំឲ្យយើងអាចឆ្លើយថាខ្ញុំជាអ្នកបម្រើរបស់ព្រះជាម្ចាស់ ខ្ញុំធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គ។

ខ្ញុំចង់ឲ្យបងប្អូនចាប់អារម្មណ៍ អំពីរបៀបដែលព្រះយេស៊ូបានព្យាបាលមនុស្សថ្លង់ ព្រះអង្គមិនបានព្យាបាលគាត់នៅមុខគេទាំងអស់ "**ព្រះយេស៊ូបាននាំគាត់ដាច់ឡែកពីបណ្តាជន**" ព្រះយេស៊ូមិនព្យាបាលគាត់ជាសាធារណៈ ព្រះអង្គបានយកគាត់ចេញពីមហាជនដើម្បីបង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយគាត់។ នៅពេលយើងអង្គុយនៅក្បែរព្រះកាយព្រះគ្រីស្ត ជាឱកាសមួយដើម្បីឲ្យយើងបង្កើតទំនាក់ទំនងជាមួយព្រះយេស៊ូ ព្រះអង្គមិននិយាយទូទៅដល់មហាជន ប៉ុន្តែព្រះយេស៊ូនិយាយជាមួយយើងផ្ទាល់។ ទំនាក់ទំនងផ្ទាល់របស់ព្រះយេស៊ូជិតស្និទ្ធណាស់ "**ព្រះអង្គយកទឹកព្រះឱស្ឋដាក់លើភ្នែកគាត់ ហើយដាក់ព្រះហស្តលើគាត់**" ព្រះអង្គបង្កើតទំនាក់ទំនងជាមួយគេដើម្បីឲ្យបានទៅជាអង្គតែមួយជាមួយព្រះយេស៊ូ។ មហាជនពេលគេស្តាប់យ៉ូហានបាទីស្ទណែនាំឲ្យគេមើលឃើញព្រះគ្រីស្តផ្ទាល់ យើងមានគំរូតែមួយគឺព្រះយេស៊ូតែម្តង។

ថ្ងៃនេះ ព្រះបន្ទូលណែនាំឲ្យយើងកក់ក្តៅណាស់ ដោយសារព្រះយេស៊ូចាប់យើងដើម្បីបង្កើតទំនាក់ទំនងជាមួយយើងផ្ទាល់ខ្លួន។ ពេលព្រះយេស៊ូប៉ះយើងហើយ ព្រះអង្គបានបង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធមែនទែន ព្រះអង្គមានអធិដ្ឋានទៅព្រះបិតា ទៅព្រះវិញ្ញាណដ៏វិសុទ្ធ

ដើម្បីឲ្យអ្នកនោះមានជីវិតដ៏ពេញលក្ខណៈ ព្រះអង្គបានឆ្លើយតបនឹងសេចក្តីត្រូវការរបស់អ្នកនោះ។ មនុស្សថ្លង់គេចង់ស្តាប់ឮ មនុស្សគរគេចង់និយាយបាន មនុស្សខ្វាក់គេចង់មើលឃើញ មនុស្សខ្វិនគេចង់ដើរបាន មនុស្សដែលដើរក្នុងទីងងឹតគេចង់រកឃើញពន្លឺ។ ដូច្នេះព្រះយេស៊ូយាងមក ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់យើង។ មុនដំបូង យើងត្រូវដឹងថាខ្លួនឯងថាយើងចង់បានអ្វី? ប៉ុន្តែ ដើម្បីដឹងថាយើងត្រូវការអ្វី ឲ្យយើងស្តាប់ព្រះយេស៊ូនៅលើឈើឆ្កាងដែលមានព្រះបន្ទូលថា "**ខ្ញុំស្រេកទឹក**" ឲ្យយើងគាត់សម្រាប់ជីវិតរបស់ខ្ញុំតើខ្ញុំត្រូវការអ្វីខ្លះដើម្បីមានសុភមង្គលយ៉ាងពិតប្រាកដ នៅពេលនោះយើងដឹងថាព្រះយេស៊ូយាងមកដើម្បីបំពេញសេចក្តីត្រូវការរបស់យើងម្នាក់ៗ។ មានមនុស្សរាប់ពាន់នាក់ដែលបានដើរតាមព្រះយេស៊ូ និងស្តាប់ព្រះអង្គទោះបីអ្នកខ្លះស្តាប់មិនសូវឮតែវត្តមានរបស់ព្រះយេស៊ូណែនាំឲ្យគេយល់ថា ព្រះអង្គនៅទីនេះដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់គេ ដោយសារព្រះអង្គចាប់អារម្មណ៍ពីគេ។ រឿងស្ត្រីដែលបានធ្លាក់ឈាម ១២ឆ្នាំហើយ បាននៅពីក្រោយព្រះយេស៊ូ ទោះបីមានមនុស្សជាង៥ពាន់នាក់ព្រះយេស៊ូដឹងថាស្ត្រីនោះបានប៉ះអាវរបស់ទ្រង់ ព្រះអង្គបានបានចាប់អារម្មណ៍អំពីគាត់ មើលគាត់ហើយនិយាយទៅកាន់គាត់និងសង្គ្រោះស្ត្រីនោះ។

ថ្ងៃនេះយើងពោរពេញដោយអំណរសប្បាយ ដោយសារយើងដឹងថាព្រះយេស៊ូយាងមកដើម្បីបង្កើតទំនាក់ទំនងជាមួយខ្ញុំ និងដើម្បីមានព្រះបន្ទូលមកខ្ញុំថា "**អេហ្វាថា ចូរបើកឡើង**" អ្វីដែលណែនាំឲ្យយើងចង្អៀតចង្អល់ អ្វីដែលណែនាំឲ្យយើងភ័យខ្លាចអស់ហើយ ដោយសារសេចក្តីស្រឡាញ់របស់ព្រះយេស៊ូ។ ពេលយើងទៅទទួលអគ្គសញ្ញាលើកលែងទោស ព្រះជាម្ចាស់មានព្រះបន្ទូលតាមរយៈលោកបូជាចារ្យថា "**ខ្ញុំសុំលើកលែងទោសកូន**" នៅពេលនោះដូចជាមានអ្វីដែលបានបើកខ្លាំងនៅក្នុងដួងចិត្តរបស់យើង យើងមានពន្លឺមួយយ៉ាងពិសេសដែលណែនាំឲ្យយើងយល់ថាយើងអាចទៅមុខ ដើម្បីចូលរួមនៅក្នុងគំរោងការណ៍ដ៏អស្ចារ្យរបស់ព្រះជាម្ចាស់។ ក្នុអត្ថបទទីពីរថ្ងៃនេះ "**សូមស្តាប់ខ្ញុំ ព្រះជាម្ចាស់បានជ្រើសរើសអ្នកក្រក្នុងលោកនេះ ឲ្យទៅជាអ្នកមានផ្នែកខាងជំនឿ និងឲ្យទទួលព្រះរាជ្យដែលទ្រង់បានសន្យាថា នឹងប្រទានឲ្យអស់អ្នកដែលស្រឡាញ់ព្រះអង្គទុកជាមរតក**"។ ព្រះយេស៊ូយាងមកដើម្បីឲ្យអ្នកក្រីក្រ ទៅជាអ្នកមានដោយសារជំនឿ នឹងណែនាំឲ្យយើងទទួលមរតក គឺជីវិតផ្ទាល់របស់ព្រះជាម្ចាស់លើផែនដីនេះ លុះត្រាតែយើងស្រឡាញ់ព្រះជាម្ចាស់។ ព្រះយេស៊ូយាងមក ដើម្បីឲ្យយើងរកឃើញសេចក្តីសុខសុភមង្គលយ៉ាងពិតប្រាកដ ជាពិសេសអំណរសប្បាយដែលចេញពីដួងចិត្តរបស់យើង ដើម្បីឲ្យយើងទៅមុខនៅក្នុងសេចក្តីសុខសាន្ត។ ព្រះជាម្ចាស់បានជ្រើសរើស ព្រះជាម្ចាស់បានការពារថែរក្សា ព្រះជាម្ចាស់បានជំរុញ ព្រះជាម្ចាស់បានលើកទឹកចិត្ត ព្រះអង្គឲ្យយើងបើកឡើងដើម្បីទៅមុខ ដើម្បីប្រកាសដំណឹងល្អ ដើម្បីចូលរួមនៅក្នុងគំរោងការណ៍ដ៏អស្ចារ្យរបស់ព្រះអង្គ។ បើយើងជួយ១០០

នាក់មិនបាន ឲ្យយើងជួយម្នាក់ដែលយើងជួយអស់ពីសមត្ថភាព កុំឲ្យយើងធ្វើជាមនុស្សខ្ជិលដូចអ្នកបម្រើដែលបានប្រាក់មួយដួងហើយយកទៅកប់នៅក្នុងដី ដោយមិនបង្កើតបានផលអ្វីសោះ។

យើងទទួលព្រះវិញ្ញាណដ៏វិសុទ្ធ ដែលជំរុញឲ្យយើងចេញពីភាពចង្អៀតចង្អល់នៃដួងចិត្តរបស់យើង ព្រះវិញ្ញាណដ៏វិសុទ្ធជំរុញយើងឲ្យយើងមានចិត្តក្លាហានដើម្បីប្រកាសដំណឹងល្អ។ យើងសង្ឃឹមយើងមានបងប្អូនថែមទៀតនៅតាមភូមិរបស់យើង ដែលរកឃើញអំណរសប្បាយយ៉ាងពិតប្រាកដតាមរយៈយើងម្នាក់ៗ បានប្រកាសអំពីព្រះបន្ទូលរបស់ព្រះអង្គ។ សូមបងប្អូនបើកឡើង ដើម្បីណែនាំឲ្យអ្នកក្រីក្រក្លាយទៅជាអ្នកមានដោយសារជំនឿ និងស្គាល់ព្រះរាជ្យរបស់ព្រះជាម្ចាស់។ យើងសង្ឃឹមថា យើងបានពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ដើម្បីបន្តរស់នៅជាសាវ័កនិងជាមិត្តសម្លាញ់របស់ព្រះយេស៊ូ ដោយហ៊ានប្រកាសដំណឹងល្អតាមរយៈជីវិតរបស់យើងប្រចាំថ្ងៃ ខ្ញុំជួយ១០០នាក់មិនបាន ខ្ញុំជួយ៥០នាក់មិនបាន ប៉ុន្តែយ៉ាងតិចខ្ញុំជួយម្នាក់ ដើម្បីឲ្យគាត់មានជីវិត។ សូមអរព្រះគុណព្រះជាម្ចាស់ សូមព្រះអង្គគង់នៅជាមួយយើងម្នាក់ៗ ដើម្បីឲ្យយើងទៅប្រកាសដំណឹងល្អនៃសេចក្តីស្រឡាញ់ នៃធម៌មេត្តាករុណារបស់ព្រះជាម្ចាស់។ អាម៉ែន៕